# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៈ០៣...សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំសន្និសីទ
## ការផ្តល់ឱកាសនៃសកលភាវូនីយកម្ម_យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងយុគសម័យនៃពាណិជ្ជកម្មសេរី
## នៅរាជធានីភ្នំពេញពី ថ្ងៃទី ១០ ដល់ ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការរៀបចំសន្និសីទ ការផ្តល់ឱកាសនៃសកលភាវូនីយកម្ម - យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងយុគសម័យនៃពាណិជ្ជកម្មសេរី ដែលនឹងប្រព្រឹត្តិទៅ ចាប់ពី ថ្ងៃទី ១០ ដល់ ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥ នៅរាជធានីភ្នំពេញដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ប៊ុណ្ណារ៉ាំ សិរីវុឌ្ឍ** | រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៤-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម **ហុក ឡុងឌី** | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម **ប៊ុន អ៊ុយ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-ឯកឧត្តម **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |

| | | |
|---|---|---|
| ៨-ឯកឧត្តម **គីម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-ឯកឧត្តម **មិន ឃិន** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | សមាជិក |
| ១០-ឯកឧត្តម **ទាវ ខាង** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-ឯកឧត្តម **កែប ជុតិមា** | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១២-ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៣-ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤-ឯកឧត្តម **ឈួន ដារ៉ា** | អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ២** : គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ :

ក- ចងក្រងរាល់ឯកសារពាក់ព័ន្ធនឹងសន្និសីទ

ខ- រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

គ- រៀបចំគំរោងចំណាយពាក់ពន្ធ័សមត្ថកិច្ចរបស់កម្ពុជា

ឃ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាពល្អ

ង- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ច- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទេសរ្សនាចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ឆ-សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះ ។

**ប្រការ៣** : ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៤** : ប្រធានគណៈកម្មការនេះ មានសិទ្ធិបង្កើតក្រុមការងារប្រតិបត្តិផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួង-ទេសចរណ៍ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ខាងលើត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ១ និងប្រការ៥
-ឯកសារ-កាលប្បវត្តិ